**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌

លេខ : ០៤៣ កយ.ប្រក/២៥

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពអាជ្ញាសាលា នៅតាមសាលាដំបូងរាជធានី ខេត្ត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
- បានឃើញប្រកាសលេខ ៣០ កយប្រក/០៧ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះកំណត់អំពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពអាជ្ញាសាលា នៅតាមសាលាដំបូងរាជធានី ខេត្ត។

**ប្រការ២ .-**

ត្រូវបានបង្កើតអង្គភាពអាជ្ញាសាលាមួយ នៅតាមសាលាដំបូងរាជធានី ខេត្ត ដែលស្ថិតក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ដោយមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការជាសេនាធិការ ដើម្បីជាយន្តការដឹកនាំ និងសម្របសម្រួលការអនុវត្តមុខងាររបស់មន្ត្រីអាជ្ញាសាលា ស្របតាមការកំណត់របស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការដាក់ឱ្យដំណើរការអង្គភាពអាជ្ញាសាលានៅតាមសាលាដំបូងរាជធានី ខេត្ត ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ប្រធានសាលាដំបូងរាជធានី ខេត្ត មានភារកិច្ចជួយសម្របសម្រួលនូវរាល់កិច្ចការរដ្ឋបាលរបស់អង្គភាពអាជ្ញាសាលា ព្រមទាំងត្រូវផ្តល់ការគាំទ្រចាំបាច់នានាសម្រាប់ជានាដល់កិច្ចដំណើរការរបស់អង្គភាពអាជ្ញាសាលានៅតាមសាលាដំបូងរបស់ខ្លួន។

**ប្រការ៣ .-**

អង្គភាពអាជ្ញាសាលាមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល និងគ្រប់គ្រងមន្ត្រីអាជ្ញាសាលា និងរាល់កិច្ចការរដ្ឋបាលពាក់ព័ន្ធនឹងការអនុវត្តមុខងាររបស់មន្ត្រីអាជ្ញាសាលា
- ទទួល និងចាត់ចែងពាក្យសុំអនុវត្តដោយបង្ខំ និងពាក្យសុំអនុវត្តរក្សាការពារ ស្របតាមការកំណត់របស់ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ជាធរមានផ្សេងទៀត
- សម្របសម្រួលជាមួយចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី កងកម្លាំង និងអាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចដំណើរការអនុវត្តសេចក្តីសម្រេចរបស់តុលាការ
- គ្រប់គ្រង និងចាត់ចែងប្រតិបត្តិការបញ្ជូន ស្របតាមការកំណត់របស់ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមានផ្សេងទៀត
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមរយៈប្រធានសាលាដំបូងរាជធានី ខេត្ត ដែលអង្គភាពអាជ្ញាសាលាស្ថិតនៅ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ប្រគល់ឱ្យ។

**ប្រការ៤ .-**

អង្គភាពអាជ្ញាសាលា ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។ ប្រធាន និងអនុប្រធាននៃអង្គភាពអាជ្ញាសាលា ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ប្រធាន និងអនុប្រធាននៃអង្គភាពអាជ្ញាសាលា ត្រូវតែងតាំងចេញពីមន្ត្រីអាជ្ញាសាលា។ ប្រធានអង្គភាពអាជ្ញាសាលា ត្រូវជ្រើសរើសចេញពីមន្ត្រីអាជ្ញាសាលាដែលមានបទពិសោធន៍ការងាររយៈពេលយ៉ាងតិចចំនួន ៥ (ប្រាំ) ឆ្នាំ។

**ប្រការ៥ .-**

ម្ចាស់បំណុលនៃការអនុវត្ត ឬអ្នកតំណាង ត្រូវដាក់ពាក្យសុំអនុវត្តសាលក្រម សាលដីកា និងដីកាសម្រេច របស់តុលាការ ទៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី ខេត្ត។

ប្រធានសាលាដំបូងរាជធានី ខេត្ត ត្រូវប្រគល់ភារកិច្ចទាំងឡាយណាដែលជាសមត្ថកិច្ចរបស់អាជ្ញាសាលា ជូនទៅអង្គភាពអាជ្ញាសាលាដែលស្ថិតនៅតាមសាលាដំបូងរបស់ខ្លួន ដើម្បីអនុវត្តការងារស្របតាមការកំណត់ របស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ រាល់សំណុំរឿងអនុវត្តដែលត្រូវបានដាក់នៅ លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី ខេត្ត ត្រូវទទួលបាននូវចំណាត់ការដោយរួសរាន់ពីសំណាក់ ប្រធានលេខាធិការដ្ឋាន និងប្រធានសាលាដំបូង ដើម្បីបែងចែកសំណុំរឿងដែលស្ថិតក្រោមសមត្ថកិច្ចរបស់ អាជ្ញាសាលា ទៅអង្គភាពអាជ្ញាសាលា។

ប្រធានអង្គភាពអាជ្ញាសាលា ពិនិត្យ និងចាត់ចែងពាក្យសុំអនុវត្តដែលជាសមត្ថកិច្ចរបស់អាជ្ញាសាលា។

**ប្រការ៦ .-**

ជាគោលការណ៍ ការបែងចែកសំណុំរឿងអនុវត្ត និងលំដាប់ជំនួសមន្ត្រីអាជ្ញាសាលាក្នុងករណីមានធុរៈ ត្រូវកំណត់ទុកជាមុនជារៀងរាល់ឆ្នាំ ដោយសេចក្តីសម្រេចរបស់ប្រធានអង្គភាពអាជ្ញាសាលា។ សំណុំរឿងអនុវត្ត ត្រូវបានបែងចែកឱ្យមន្ត្រីអាជ្ញាសាលាម្នាក់ៗទទួលបន្ទុកជាស្វ័យប្រវត្តិ ទៅតាមលំដាប់ដែលត្រូវបានកំណត់។ ក្នុងករណីចាំបាច់ និងដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្ត សំណុំរឿងអនុវត្តអាចត្រូវបែងចែកផ្សេងពីនេះ ដោយប្រធានអង្គភាពអាជ្ញាសាលា។

ក្នុងករណីដែលសំណុំរឿងអនុវត្តមានភាពស្មុគស្មាញ ប្រធានអង្គភាពអាជ្ញាសាលាអាចចាត់តាំងមន្ត្រី អាជ្ញាសាលាបន្ថែមមួយ ឬច្រើនរូប ដើម្បីជួយដល់មន្ត្រីអាជ្ញាសាលាទទួលបន្ទុកសំណុំរឿងអនុវត្ត តាមសំណើ របស់មន្ត្រីអាជ្ញាសាលាសាមី ឬតាមគំនិតផ្តើមរបស់ខ្លួន បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយមន្ត្រីអាជ្ញាសាលា សាមី។ ក្នុងករណីនេះ មន្ត្រីអាជ្ញាសាលាជំនួយ ត្រូវធ្វើការក្រោមការដឹកនាំ និងការសម្របសម្រួលរបស់ មន្ត្រីអាជ្ញាសាលាទទួលបន្ទុកសំណុំរឿងអនុវត្ត។

ការដកហូតសំណុំរឿងអនុវត្តពីមន្ត្រីអាជ្ញាសាលាណាមួយ ដើម្បីប្រគល់ជូនមន្ត្រីអាជ្ញាសាលាណាមួយទៀត អាចធ្វើឡើងដោយប្រធានអង្គភាពអាជ្ញាសាលា ដើម្បីជាប្រយោជន៍ដល់ដំណើរការល្អនៃយុត្តិធម៌ តាមសំណើ របស់មន្ត្រីអាជ្ញាសាលាសាមី ឬតាមការផ្តើមគំនិតផ្ទាល់ខ្លួន បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយមន្ត្រីអាជ្ញាសាលា សាមី និងប្រធានសាលាដំបូង។

**ប្រការ៧ .-**

ប្រធានសាលាដំបូងរាជធានី ខេត្ត និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្ត ត្រូវផ្តល់ កិច្ចសហការ និងការគាំទ្រចាំបាច់នានាដល់អង្គភាពអាជ្ញាសាលា ក្នុងការអនុវត្តមុខងាររបស់មន្ត្រីអាជ្ញាសាលា ឱ្យមានប្រសិទ្ធភាព។

ប្រធានអង្គភាពអាជ្ញាសាលា មានសិទ្ធិកេណ្ឌកម្លាំងសាធារណៈដើម្បីចូលរួមអនុវត្ត និងសហការអនុវត្ត មុខងាររបស់មន្ត្រីអាជ្ញាសាលាស្របតាមច្បាប់ជាធរមាន។

**ប្រការ៨ .-**

រាល់ការអនុវត្តដោយបង្ខំទាំងឡាយណាដែលអាចបង្កើតឱ្យមាននូវភាពចលាចល ឬភាពវឹកវរ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ប្រធានអង្គភាពអាជ្ញាសាលា ត្រូវធ្វើការពិគ្រោះយោបល់ជាមួយប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ ហើយក្នុងករណីចាំបាច់ ត្រូវស្នើសុំគោលការណ៍ណែនាំជាមុនពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៩ .-**

មន្ត្រីដែលបំពេញការងារនៅក្នុងអង្គភាពអាជ្ញាសាលា មានមន្ត្រីអាជ្ញាសាលា និងមន្ត្រីរាជការនៃអង្គភាពរដ្ឋបាលតុលាការ។ អង្គភាពអាជ្ញាសាលាអាចមានមន្ត្រីជាប់កិច្ចសន្យា ឬបុគ្គលិកជាប់កិច្ចសន្យាមួយចំនួនតាមការចាំបាច់ ដើម្បីជួយការងារ។

មន្ត្រីរាជការក្របខ័ណ្ឌ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកជាប់កិច្ចសន្យាអាចត្រូវបានចាត់តាំងជាមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន ដើម្បីជួយចាត់ចែងប្រតិបត្តិការបញ្ជូន និងជួយការងារផ្សេងទៀត។

**ប្រការ១០ .-**

ក្នុងការអនុវត្តកិច្ចការបញ្ជូន អាជ្ញាសាលាត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិភូកម្មនូវមុខងារនេះ ដើម្បីអនុវត្តប្រតិបត្តិការបញ្ជូននេះជំនួសខ្លួន ដោយអនុវត្តទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

មន្ត្រីដែលទទួលបានការប្រតិភូកម្មនូវមុខងារនេះ ហៅថា "មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន"។ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន ត្រូវទទួលបានការតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានអង្គភាពអាជ្ញាសាលា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានសាលាដំបូង ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន អាចត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ឬបុគ្គលិកជាប់កិច្ចសន្យា។ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន ត្រូវទទួលបាននូវការបណ្តុះបណ្តាលជាចាំបាច់អំពីបែបបទ និងនីតិវិធីនៃការអនុវត្តកិច្ចការបញ្ជូន។

មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន ត្រូវអនុវត្តការងារក្រោមការដឹកនាំដោយផ្ទាល់របស់ប្រធានអង្គភាពអាជ្ញាសាលា ឬមន្ត្រីអាជ្ញាសាលាតាមការចាត់តាំងរបស់ប្រធានអង្គភាពអាជ្ញាសាលា។ ប្រធានអង្គភាពអាជ្ញាសាលា ឬមន្ត្រីអាជ្ញាសាលាដែលទទួលបានការចាត់តាំងលើកិច្ចការនេះ ត្រូវទទួលខុសត្រូវចំពោះការអនុវត្តកិច្ចការបញ្ជូនដោយផ្អែកតាមច្បាប់និងនីតិវិធីជាធរមាន។

ប្រធានអង្គភាពអាជ្ញាសាលា ត្រូវទទួលខុសត្រូវចំពោះមុខប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ចំពោះកិច្ចការបញ្ជូន។

៤

**ប្រការ១១ .-**

អង្គភាពអាជ្ញាសាលាប្រើប្រាស់រូបសញ្ញារបស់សាលាដំបូងក្នុងការអនុវត្តមុខងាររបស់ខ្លួន។ មន្ត្រីអាជ្ញាសាលាមានឯកសណ្ឋានសម្រាប់បំពេញមុខងាររបស់ខ្លួន ដែលត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

អង្គភាពអាជ្ញាសាលា មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាដំបូងដែលអង្គភាពអាជ្ញាសាលាតាំងនៅសម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

**ប្រការ១២ .-**

ចំពោះសាលាដំបូងដែលមិនទាន់មានអង្គភាពអាជ្ញាសាលា ត្រូវបន្តអនុវត្តតាមប្រកាសលេខ ៣០ កយប្រក/០៧ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។

**ប្រការ១៣ .-**

ប្រកាសលេខ ០៦២ កយ.ប្រក/១៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ស្ដីពីបែបបទសម្រាប់អនុវត្តការងាររបស់មន្ត្រីអាជ្ញាសាលា នៃក្រសួងយុត្តិធម៌ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ សាលាជម្រះក្ដី និងអង្គការអយ្យការអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។៚

ថ្ងៃ អង្គារ ១២កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កើត រិទ្ធ

**កន្លែងទទួល ៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ